**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០៦៤ ពណ.សរ.ជ.ប្រក

# ប្រកាស

## ស្តីពី

## ការកំណត់ភារកិច្ចជូនមន្ត្រីជាន់ខ្ពស់ នៃក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៧៨ ពណ.នច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននាំចេញនាំចូល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលភារកិច្ចមន្ត្រីជាន់ខ្ពស់នៃក្រសួងពាណិជ្ជកម្ម ដែលមានសិទ្ធិចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ សម្រាប់នាំចេញទំនិញពីកម្ពុជាទៅកាន់ទីផ្សារពិភពលោក សំដៅសម្រួលនីតិវិធីផ្ទៃក្នុង និងកាត់បន្ថយពេលវេលាក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ជូនក្រុមហ៊ុននាំចេញ។

**ប្រការ ២.-**

ត្រូវបានប្រគល់ភារកិច្ចជូនរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ឲ្យពិនិត្យសម្រេច និងចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ «អេ» (A) សម្រាប់ការនាំចេញទំនិញតាមជើងយន្តហោះ ទៅកាន់ទីផ្សារពិភពលោក។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ ៣.-**

ត្រូវបានប្រគល់ភារកិច្ចជូនអគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ពិនិត្យសម្រេចចុះហត្ថលេខា និងប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម លើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់សម្រាប់ការនាំចេញទំនិញទៅកាន់ទីផ្សារពិភពលោក លើកលែងតែទម្រង់ «អ៊ិន និងឌី» (N & D) ទំនិញមានបរិមាណតិចតួចសម្រាប់យកទៅធ្វើគំរូ ទំនិញនាំចេញទៅកាន់សហភាពអឺរ៉ុបដែលមានតម្លៃស្មើ ឬក្រោម ៦ ០០០ (ប្រាំមួយពាន់) អឺរ៉ូ និងទំនិញនាំចេញតាមជើងយន្តហោះដូចមានចែងក្នុងប្រការ២។

**ប្រការ ៤.-**

ត្រូវបានប្រគល់ភារកិច្ចជូនប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាននាំចេញ-នាំចូលនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ពិនិត្យសម្រេចចុះហត្ថលេខា និងប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម លើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ទម្រង់ «អ៊ិន និងឌី» (N & D) និងទំនិញដែលមានបរិមាណតិចតួចសម្រាប់យកទៅធ្វើគំរូ ទំនិញនាំចេញទៅបរទេសដែលមានតម្លៃស្មើ ឬក្រោម ៦ ០០០(ប្រាំមួយពាន់) អឺរ៉ូ សម្រាប់ការនាំចេញទំនិញទៅកាន់ទីផ្សារពិភពលោក លើកលែងតែវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដូចមានចែងក្នុងប្រការ២ និងប្រការ៣ ។

**ប្រការ ៥.-**

តាមការចាំបាច់ និងសំដៅសម្រួលពាណិជ្ជកម្ម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អាចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់បាន។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១០រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សភាពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធស្រូវអង្ករកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ